ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៦១ ឧ៨

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ជូនអាជីវកម្មទីភ្នាក់ងារទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ / នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក. ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- យោងសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១ :** -អាជីវកម្មទីភ្នាក់ងារទេសចរណ៍ គឺជាអាជីវកម្មទាក់ទងនឹងសកម្មភាពសេវាកម្មរៀបចំខ្សែទស្សនកិច្ច ផ្តល់សេវាស្នាក់នៅ ម្ហូបអាហារ មធ្យោបាយដឹកជញ្ជូន និងសេវាទេសចរណ៍នានាជូនទេសចរ ។

-សាខាទីភ្នាក់ងារទេសចរណ៍ គឺជាសាខាតំណាងអោយទីភ្នាក់ងារទេសចរណ៍ និង ធ្វើសកម្មភាពក្នុងដែនកំណត់ដែលមានការយល់ព្រមតាមកិច្ចសន្យា ។

# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥) ២៣ ២១៣ ៧៤១ ទូរសារ: (៨៥៥) ២៣ ២២០ ៧០៤, អ៊ីមែល: info@mot.gov.kh Website: www.mot.gov.kh

ប្រការ ២ : អាជីវកម្មទីភ្នាក់ងារទេសចរណ៍ ត្រូវបានប្រតិបត្តិការដោយការីទេសចរណ៍ ឬ ភ្នាក់ងារទេសចរណ៍ :

- ការីទេសចរណ៍ សំដៅដល់រូបវន្តបុគ្គល ឬ និតិបុគ្គលធ្វើអាជីវកម្មរៀបចំ និងលក់កញ្ចប់ខ្សែទស្សនកិច្ច ព្រមទាំងលក់បណ្ណសេវាកម្មទេសចរណ៍ដោយផ្ទាល់ ឬ ដោយប្រយោលតាមរយៈភ្នាក់ងារទេសចរណ៍ ឬ ភាគីផ្សេងទៀតក្នុងកិច្ចសន្យា។
- ភ្នាក់ងារទេសចរណ៍ សំដៅលើរូបវន្តបុគ្គល ឬនិតិបុគ្គលធ្វើអាជីវកម្មទទួលលក់សំបុត្រសំរាប់មធ្យោបាយធ្វើដំណើរ លក់កញ្ចប់ខ្សែទស្សនកិច្ច ដែលរៀបចំដោយការីទេសចរណ៍ និងសម្រួលបែបបទធ្វើដំណើរ។

ប្រការ ៣ : ការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍អោយប្រកបអាជីវកម្មទីភ្នាក់ងារទេសចរណ៍ ឬ សាខា និងការផ្អាក ការដកហូត បិទអាជីវកម្ម ជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ ។

ប្រការ ៤ : ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវតំកល់ប្រាក់ធានាអាជីវកម្ម នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ជាសាច់ប្រាក់រូបិយប័ណ្ណបរទេសចំនួន ៥០០០ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិក)។ ប្រាក់តំកល់នេះអាជីវករអាចដាក់ពាក្យសុំដកវិញបាននៅពេលសុំបញ្ឈប់ប្រកបអាជីវកម្ម និងមានការយល់ព្រមពីក្រសួងទេសចរណ៍។ ការដាក់ពាក្យសុំបិទអាជីវកម្ម ម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវបញ្ជាក់អំពីមូលហេតុអោយបានច្បាស់លាស់ និងមានធ្វើប្រកាសបិទផ្សាយជាសាធារណៈ ព្រមទាំងត្រូវធ្វើកិច្ចសន្យាធានាទទួលខុសត្រូវចំពោះមុខច្បាប់ ករណីមានការពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុទាក់ទងទៅនឹងសេវាកម្មទេសចរណ៍ផ្សេងៗរបស់ខ្លួនកន្លងមក ។

ប្រការ ៥ : ការរៀបចំស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីធ្វើអាជីវកម្មទីភ្នាក់ងារទេសចរណ៍ ត្រូវធ្វើឡើងដោយម្ចាស់ ឬ អ្នកទទួលខុសត្រូវគ្រប់គ្រង និងត្រូវអនុវត្តទៅតាមបែបបទដែលបានកំណត់ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួន និងមានល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ថតចំលង)

ខ- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

គ- លិខិតបញ្ជាក់ការតំកល់ប្រាក់ធានាអាជីវកម្ម ពីធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ដូចមានចែងក្នុងប្រការ ៤ ខាងលើ

ឃ- លិខិតបញ្ជាក់ទីស្នាក់ការ ឬ កិច្ចសន្យាជួលផ្ទះ ដោយមានការបញ្ជាក់ពីអាជ្ញាធរដែនដី

ង- លិខិតធានារ៉ាប់រង

ច- ការយល់ព្រមរបស់ម្ចាស់ ឬទីភ្នាក់ងារទេសចរណ៍ ក្នុងករណីអ្នកគ្រប់គ្រងមិនមែនជាម្ចាស់នៃទីភ្នាក់ងារទេសចរណ៍ ឬសាខាទីភ្នាក់ងារទេសចរណ៍

ឆ- សញ្ញាប័ត្រ ឬវិញ្ញាប័នប័ត្រ របស់អ្នកគ្រប់គ្រងដែលបញ្ជាក់ការសិក្សាមុខជំនាញបដិសណ្ឋារកិច្ច ឬ គ្រប់គ្រងទេសចរណ៍ ។

ប្រការ ៦ : អាជ្ញាប័ណ្ណអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និង សាខា ត្រូវបានចេញអោយចំពោះឈ្មោះម្ចាស់ ឬ អ្នកគ្រប់គ្រងដែលជាអ្នកស្នើសុំ ក្រោយពីបានបំពេញសំណុំឯកសារក្នុងការដាក់ពាក្យសុំបើកអាជីវកម្មគ្រប់គ្រាន់ និងត្រឹមត្រូវ

យ៉ាងយូរក្នុងរយៈពេល ២៨ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានដាក់ពាក្យ ។ ក្នុងករណីដែលក្រសួងបដិសេធមិនផ្តល់ ឬ មិនបន្តអាជ្ញាប័ណ្ណទេសចរណ៍ ក្រសួងនឹងបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរដល់អ្នកស្នើសុំមិនលើសពី ១០ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យ ។

**ប្រការ ៧ :** នៅពេលអ្នកស្នើសុំអាជ្ញាប័ណ្ណដំបូងបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវទៅតាមបែបបទដូចមានកំណត់ក្នុងប្រការ ៥ ខាងលើ ក្រសួងនឹងចេញអាជ្ញាប័ណ្ណទេសចរណ៍សំរាប់ធ្វើអាជីវកម្មដែលមានសុពលភាពរយៈពេល ០១ ឆ្នាំ ។

**ប្រការ ៨ :** ពេលមានការបិទអាជីវកម្ម ផ្លាស់ប្តូរទីតាំងអាជីវកម្ម ផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវដាក់ពាក្យសុំមកក្រសួងទេសចរណ៍អោយបានមុន ០៣ ខែ ។

**ប្រការ ៩ :** ការបង់ប្រាក់សុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីសុំប្រកបអាជីវកម្មដំបូង ឬ បន្តត្រូវបានកំណត់ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ក ~ | អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការកណ្តាលៈ | | |
| | - អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការកណ្តាល | សំរាប់ឆ្នាំដំបូង | ១.២០០.០០០ រៀល |
| | - អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការកណ្តាល | សំរាប់ឆ្នាំបន្ត | ៦០០.០០០ រៀល |
| ខ ~ | អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការសាខាៈ | | |
| | - អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការសាខា | សំរាប់ឆ្នាំដំបូង | ៨០០.០០០ រៀល |
| | - អាជ្ញាប័ណ្ណទេសចរណ៍បើកស្នាក់ការសាខា | សំរាប់ឆ្នាំបន្ត | ៤០០.០០០ រៀល |
| គ ~ | - ការផ្លាស់ប្តូរឈ្មោះអ្នកគ្រប់គ្រង | ត្រូវបង់ | ១២០.០០០ រៀល |

**ប្រការ ១០:** ម្ចាស់ ឬអ្នកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ និងសាខាត្រូវដាក់ពាក្យសុំដំបូង ឬបន្ត ព្រមទាំងទទួលយកអាជ្ញាប័ណ្ណទេសចរណ៍ នៅមន្ទីរទេសចរណ៍ខេត្ត-ក្រុង។ មន្ទីរទេសចរណ៍ត្រូវទទួលពាក្យសុំ និងត្រួតពិនិត្យ ហើយបញ្ជូនមកក្រសួងទេសចរណ៍ក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ។ ក្រសួងទេសចរណ៍ (នាយកដ្ឋានឧស្សាហកម្មទេសចរណ៍) ត្រូវទទួលពិនិត្យពាក្យសុំនេះ ហើយស្នើសុំការសំរេចចេញអាជ្ញាប័ណ្ណទេសចរណ៍ពីប្រធានស្ថាប័នក្នុងរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ។ ករណីចាំបាច់ ក្រសួងទេសចរណ៍អាចចុះត្រួតពិនិត្យឡើងវិញលើមូលដ្ឋានអាជីវកម្មនោះក្នុងរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលពាក្យ។ ក្រសួងទេសចរណ៍នឹងបញ្ជូនអាជ្ញាប័ណ្ណទេសចរណ៍ដែលរួចជាស្ថាពរទៅមន្ទីរទេសចរណ៍ក្នុងរយៈពេល ០៣ ថ្ងៃ។

**ប្រការ ១១:** អាជ្ញាប័ណ្ណទេសចរណ៍មានសុពលភាពប្រើប្រាស់សំរាប់រយៈពេល០១ឆ្នាំ គិតពីថ្ងៃចេញច្បាប់អនុញ្ញាត។ មុនពេលផុតសុពលភាពអាជ្ញាប័ណ្ណ ទីភ្នាក់ងារទេសចរណ៍ និង សាខាត្រូវដាក់ពាក្យសុំបន្តតាមរយៈមន្ទីរទេសចរណ៍មកក្រសួងទេសចរណ៍ ដោយភ្ជាប់មកជាមួយនូវអាជ្ញាប័ណ្ណចាស់ និងប័ណ្ណពន្ធប៉ាតង់អោយបាន០១ ខែមុនថ្ងៃផុតកំណត់។ ក្នុងរយៈពេលដែលបានដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ អ្នកស្នើសុំជាម្ចាស់អាជ្ញាប័ណ្ណនៅតែមានសិទ្ធិធ្វើអាជីវកម្មរហូតដល់ថ្ងៃដែលក្រសួងពិនិត្យសំរេច លើលក្ខណៈសម្បត្តិ និងល័ក្ខខ័ណ្ឌក្នុងការផ្តល់អាជ្ញាប័ណ្ណអោយបន្តអាជីវកម្ម ។

ប្រការ ១២:- ម្ចាស់អាជ្ញាប័ណ្ណទីភ្នាក់ងារទេសចរណ៍ និងសាខា មិនត្រូវអនុញ្ញាតអោយបុគ្គល ឬទីភ្នាក់ងារទេសចរណ៍ ឬ សាខាដទៃ ប្រើប្រាស់នាមករណ៍អាជ្ញាប័ណ្ណរបស់ខ្លួនឡើយ ។

- មិនអនុញ្ញាតអោយម្ចាស់ ឬ អ្នកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ និងសាខា ធ្វើប្រតិបត្តិការឈរឈ្មោះតំណាងអោយទីភ្នាក់ងារទេសចរណ៍ ឬ សាខាក្រៅពីទីភ្នាក់ងារទេសចរណ៍ និងសាខារបស់ខ្លួនឡើយ។

ប្រការ ១៣:- ទីភ្នាក់ងារទេសចរណ៍ និងសាខា ដែលទទួលបានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនេះអោយបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមការណែនាំរបស់ក្រសួងទេសចរណ៍។ ត្រូវដាក់តាំងអាជ្ញាប័ណ្ណនៅកន្លែងទទួលភ្ញៀវ។

- ករណីមានការខូចខាត ឬ បាត់បង់អាជ្ញាប័ណ្ណទេសចរណ៍ សាមីខ្លួនត្រូវធ្វើលិខិតជាលាយល័ក្ខអក្សរបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋាន ដើម្បីស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍បណ្តោះអាសន្នឡើងវិញ ក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់ ។

ប្រការ ១៤: - ករណីធ្វើអាជីវកម្មដោយៈ

ក) ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬ អនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលនូវការដាក់ពិន័យមានចំនួនទឹកប្រាក់ ២០០ ភាគរយ ( ពីររយភាគរយ ) នៃថ្លៃបង់ឆ្នាំដំបូង។ ប្រសិនបើអាជីវករមិនបង់ប្រាក់ផាកពិន័យនេះក្នុងរយៈពេល០៣ខែ ក្រសួងទេសចរណ៍នឹងផ្អាកការធ្វើអាជីវកម្ម ឬ ដកហូតអាជ្ញាប័ណ្ណទេសចរណ៍មិនអនុញ្ញាតអោយប្រកបអាជីវកម្មទៀតឡើយ ។

ខ) ការធ្វើអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ អាជីវករនឹងត្រូវទទួលនូវការព្រមានជាលាយល័ក្ខអក្សរ បិទអាជីវកម្ម។

គ) ក្រសួងទេសចរណ៍រកឃើញថា ទីភ្នាក់ងារទេសចរណ៍ និងសាខា បានផ្តល់ព័ត៌មានមិនពិត ឬ ប្រឌិតឯកសារពាក់ព័ន្ធនឹងពាក្យសុំធ្វើអាជីវកម្មក្រសួងទេសចរណ៍មានសិទ្ធិផ្អាកអាជីវកម្ម ឬដកហូតអាជ្ញាប័ណ្ណទេសចរណ៍ មិនអោយធ្វើអាជីវកម្ម ។

ឃ) អាជីវករប្រព្រឹត្តល្មើសនឹងច្បាប់បញ្ញត្តិទាំងឡាយរបស់រដ្ឋនឹងត្រូវដកហូតអាជ្ញាប័ណ្ណបិទអាជីវកម្ម និងត្រូវទទួលទោសតាមច្បាប់រដ្ឋ។

ប្រការ ១៥: នៅពេលទីភ្នាក់ងារទេសចរណ៍ និង សាខា ត្រូវបានផ្អាក ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្ម ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងផ្ញើដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដើម្បីទទួលប្រតិបត្តិតាម។ ក្នុងករណីសេចក្តីជូនដំណឹងនេះមិនអាចផ្ញើបានទៅដល់ម្ចាស់ ឬ អ្នកគ្រប់គ្រងដោយប្រការណាមួយ ឬ ក៏សាមីខ្លួនជាម្ចាស់ ឬ អ្នកគ្រប់គ្រងបដិសេធមិនព្រមទទួលស្គាល់ សេចក្តីជូនដំណឹងនេះត្រូវបិទនៅខាងមុខក្រុមហ៊ុន ឬ មូលដ្ឋានអាជីវកម្មហើយផ្ញើដល់គ្រប់សមាគមទេសចរណ៍នៅក្នុងស្រុក និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីទុកជាព័ត៌មាន។

ប្រការ ១៦: - ការផ្អាក ឬដកហូតអាជ្ញាប័ណ្ណទីភ្នាក់ងារទេសចរណ៍ និងសាខា មានរយៈពេលកំណត់មិនលើសពី០៦ ខែ ។ ក្នុងរយៈពេលនេះ ទីភ្នាក់ងារទេសចរណ៍ និង សាខាមិនត្រូវបានអនុញ្ញាតអោយធ្វើប្រតិបត្តិការអាជីវកម្មឡើយ

ក្រោយពីផុតកំណត់ពេលផ្អាក ឬ ដកហូត ម្ចាស់ ឬអ្នកគ្រប់គ្រង ត្រូវធ្វើលិខិតស្នើសុំមកក្រសួងទេសចរណ៍ដើម្បីសុំដំណើរការអាជីវកម្មឡើងវិញ ។

**ប្រការ ១៧:** បុគ្គលណាមួយដែលរារាំងដល់ការងារត្រួតពិនិត្យ ឬ ផ្តល់អាជ្ញាប័ណ្ណមិនត្រឹមត្រូវផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ក្រសួងទេសចរណ៍ នឹងត្រូវទទួលនូវវិធានការរដ្ឋបាល ឬ ទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១៨:** ០៣ ខែ ក្រោយពីការចុះហត្ថលេខាលើប្រកាសនេះ ក្រសួងទេសចរណ៍នឹងមិនអនុញ្ញាតអោយមានអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងសាខា ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ទៀតឡើយ ។

**ប្រការ ១៩:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២០:** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

វ៉េង ខួន

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលា ខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- គ្រប់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង (ដើម្បីមុខការ)
- គ្រប់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍

  " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ